01553405

E460

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**

**Royaume du Cambodge**
**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de première instance

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 28 / 12 / 2017
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

សំណុំរឿងលេខ៖ ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| នៅចំពោះមុខ៖ | ចៅក្រម **និល ណុន** ប្រធាន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម Claudia FENZ |
| | ចៅក្រម **យូរ ឧត្តរា** |
| កាលបរិច្ឆេទ៖ | ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៧ |
| ភាសាដើម៖ | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ៖ | សាធារណៈ |

# ដីកាចាត់តាំងអ្នកជំនាញដើម្បីវាយតម្លៃលើសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ និងដីកាកំណត់កាលបរិច្ឆេទនៃការវាយតម្លៃ

**សហព្រះរាជអាជ្ញា៖**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ
Marie GUIRAUD

**ជនជាប់ចោទ៖**

នួន ជា
ខៀវ សំផន

**សហមេធាវីការពារក្តី៖**

សុន អរុណ
Victor KOPPE
គង់ សំអុន
Anta GUISSÉ

## ១. សេចក្តីផ្តើម

១. អនុលោមតាមវិធាន ៣២ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យអ្នកជំនាញធ្វើការវាយតម្លៃផ្នែកវេជ្ជសាស្ត្រ និងផ្នែកចិត្តសាស្ត្រទៅលើជនជាប់ចោទដើម្បីបញ្ជាក់ឱ្យបានច្បាស់ថា នួន ជា និង ខៀវ សំផន នៅតែមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការប្រកាសសាលក្រមនៅក្នុងសំណុំរឿង ០០២/០២។

## ២. សំអាងហេតុ

២. អង្គជម្រះសាលាដំបូងតាមឆន្ទានុសិទ្ធិរបស់ខ្លួន អាចតែងតាំងអ្នកជំនាញដើម្បីធ្វើការវាយតម្លៃសម្បទាផ្នែករាងកាយ ឬ បញ្ញាស្មារតីរបស់ជនជាប់ចោទ[1]។ កាលពីមុន អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចចំនួនប្រាំទាក់ទងនឹងការវាយតម្លៃសម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការ[2] និងសេចក្តីសម្រេចចំនួនបីទាក់ទងនឹងវាយតម្លៃសម្បទារបស់ ខៀវ សំផន ក្នុងការចូលរួមសវនាការ[3] ដោយអង្គជំនុំជម្រះបានធ្វើការសន្និដ្ឋានជារៀងរាល់លើកថា ជនជាប់ចោទនីមួយៗមានសមត្ថភាពពេញលេញក្នុងការចូលរួមសវនាការក្នុងសំណុំរឿង ០០២។ សេចក្តីសម្រេចថ្មីៗបំផុតដែលបានចេញនៅថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៦ ផ្អែកទៅលើការពិនិត្យរបស់អ្នកជំនាញនៅក្នុងខែ កក្កដា ឆ្នាំ២០១៦[4] ដែលនៅក្នុងអំឡុងពេលនោះ អ្នកជំនាញពុំបានរក

---

[1] វិធាន ៣១ និងវិធាន ៣២ នៃវិធានផ្ទៃក្នុង។

[2] សេចក្តីសម្រេចលើកទីប្រាំស្តីពីសម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ និងដីកាបង្គាប់ឱ្យធ្វើតេស្តទៅលើបញ្ញាស្មារតីប្រចាំត្រីមាស ឯកសារ E389/5 ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៦។ សេចក្តីសម្រេចលើកទីបួនទៅលើសម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ ឯកសារ E329/7 ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៥។ សេចក្តីសម្រេចលើសម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ ឯកសារ E301/11 ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤។ សេចក្តីសម្រេចលើកទីពីរលើកាយសម្បទា និងបញ្ញាស្មារតីរបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ ឯកសារ E256/5 ចុះថ្ងៃទី២ ខែមេសា ឆ្នាំ ២០១៣។ សេចក្តីសម្រេចលើសម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការ និងលើសំណើរបស់ក្រុមមេធាវីការពារក្តី សុំចាត់តាំងអ្នកជំនាញវេជ្ជសាស្ត្របន្ថែម ឯកសារ E115/3 ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១។

[3] សេចក្តីសម្រេចលើកទីបីស្តីពីសម្បទារបស់ជនជាប់ចោទ ខៀវ សំផន ក្នុងការចូលរួមសវនាការ និងដីកាបង្គាប់ឱ្យធ្វើតេស្តទៅលើបញ្ញាស្មារតីប្រចាំត្រីមាស ឯកសារ E389/6 ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៦។ សេចក្តីសម្រេចលើកទីពីរលើសម្បទារបស់ជនជាប់ចោទ ខៀវ សំផន ក្នុងការចូលរួមសវនាការ ឯកសារ E329/8 ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៥។ សេចក្តីសម្រេចលើសម្បទារបស់ជនជាប់ចោទ ខៀវ សំផន ក្នុងការចូលរួមសវនាការ ឯកសារ E301/12 ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤។

[4] របាយការណ៍របស់អ្នកជំនាញវេជ្ជសាស្ត្រ នួន ជា ឯកសារ E389/3 ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦ ("របាយការណ៍ស្តីពី នួន ជា")។ របាយការណ៍របស់អ្នកជំនាញវេជ្ជសាស្ត្រ ខៀវ សំផន ឯកសារ E389/4 ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦ ("របាយការណ៍ស្តីពី ខៀវ សំផន")។

ឃើញភស្តុតាងណាមួយបង្ហាញថា ជនជាប់ចោទនីមួយៗមានការចុះខ្សោយផ្នែកបញ្ញាស្មារតីខុសពីធម្មតានៃបញ្ញាស្មារតីរបស់មនុស្សដែលមានអាយុ និងសាវតារដូចពួកគាត់នោះឡើយ ហើយអ្នកជំនាញក៏បានរកឃើញថា ជនជាប់ចោទទាំងពីរមានសុខភាពល្អបើគិតពីអាយុ និងស្ថានភាពវេជ្ជសាស្ត្ររបស់ពួកគាត់[5]។ ទោះបីជាយ៉ាងនេះក្តី អ្នកជំនាញបានរកឃើញថា ការចងចាំ និងមុខងារបញ្ញាស្មារតីរបស់ជនជាប់ចោទទាំងពីរអាចនឹងធ្លាក់ចុះជាបន្តបន្ទាប់ទៅតាមអាយុរបស់ពួកគាត់ និងបានផ្តល់អនុសាសន៍ថា ជនជាប់ចោទទាំងពីរគួរតែធ្វើការពិនិត្យមុខងារបញ្ញាស្មារតីឱ្យបានទៀងទាត់[6]។

៣. ផ្អែកទៅលើអនុសាសន៍របស់អ្នកជំនាញ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ថា មុខងារបញ្ញាស្មារតីរបស់ជនជាប់ចោទត្រូវតែបន្តធ្វើការវាយតម្លៃជាទៀងរាល់បីខែម្តង ដោយប្រើប្រាស់តេស្តលើបញ្ញាស្មារតីជាទៀងទាត់ក្នុងទម្រង់ជាតេស្តសង្ខេបលើបញ្ញាស្មារតី (AMT)[7]។ ផ្អែកទៅលើការពិនិត្យចុងក្រោយបំផុតកាលពីថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៧ នួន ជា បានទទួលពិន្ទុ ៧/១០ ចំណែក ខៀវ សំផន បានទទួលពិន្ទុ ១០/១០។ ពិន្ទុ ៧ ឬ លើសពីនេះបង្ហាញថាមានសភាពធម្មតា។ សុខភាពរបស់ជនជាប់ចោទក៏ត្រូវបានពិនិត្យមើលឡើងវិញជាទៀងរាល់ សប្តាហ៍ផងដែរដោយអង្គភាពពេទ្យនៃ អ.វ.ត.ក.។

៤. ក្រោយពីពិនិត្យឃើញសុខភាពរបស់ជនជាប់ចោទមានលំនឹង និងក្រោយពីបញ្ចប់សវនាការក្នុងសំណុំរឿង ០០២/០២ រួចហើយនោះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា អង្គជំនុំជម្រះមិនចាំបាច់កំណត់កាលបរិច្ឆេទក្នុងការពិនិត្យសម្បទារបស់ជនជាប់ចោទនៅក្នុងឆ្នាំ ២០១៧ នោះឡើយ។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះសាលាដំបូងនឹងកំណត់កាលបរិច្ឆេទក្នុងការពិនិត្យសម្បទារបស់ជនជាប់ចោទនៅដើមឆ្នាំ ២០១៨ ក្នុងគោលបំណងដើម្បីធានាថា ជនជាប់ចោទអាចចូលរួមបានពេញលេញនៅក្នុងសវនាការប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០២។

---

[5] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ៤១ ដល់ កថាខណ្ឌ ៤៧ ទំព័រ ១០ ដល់ ទំព័រ ១១។ របាយការណ៍ស្តីពី ខៀវ សំផន កថាខណ្ឌ ២ ដល់ កថាខណ្ឌ ៨ ទំព័រ ១០ ដល់ ទំព័រ ១១។

[6] របាយការណ៍ស្តីពី នួន ជា កថាខណ្ឌ ៤៧។ របាយការណ៍ស្តីពី ខៀវ សំផន កថាខណ្ឌ ៨ ទំព័រ ១១។

[7] សេចក្តីសម្រេចលើកទីប្រាំស្តីពីសម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ និងដីកាបង្គាប់ឱ្យធ្វើតេស្តទៅលើបញ្ញាស្មារតីប្រចាំត្រីមាស ឯកសារ E389/5 ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៦ កថាខណ្ឌ ១៣។ សេចក្តីសម្រេចលើកទីបីស្តីពីសម្បទារបស់ជនជាប់ចោទ ខៀវ សំផន ក្នុងការចូលរួមសវនាការ និងដីកាបង្គាប់ឱ្យធ្វើតេស្តទៅលើបញ្ញាស្មារតីប្រចាំត្រីមាស ឯកសារ E389/6 ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៦ កថាខណ្ឌ ១៣។ ដីកាបង្គាប់ឱ្យធ្វើតេស្តទៅលើបញ្ញាស្មារតីរបស់ជនជាប់ចោទប្រចាំត្រីមាស និងកំណត់ពេលវេលានៃការធ្វើតេស្ត ឯកសារ E389/5/2 ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៧។

## ៣. ការចាត់តាំងអ្នកជំនាញ និងដីកាបង្គាប់

៥. អង្គជំនុំជម្រះសាលាដំបូងសម្រេចចាត់តាំងវេជ្ជបណ្ឌិត CHAN Kin Ming ដែលមានជំនាញខាងព្យាបាលថែទាំមនុស្សចាស់ និងវេជ្ជបណ្ឌិត ហួត លីនណា ដែលមានជំនាញផ្នែកវិកលវិទ្យា (ជារួមហៅថា "អ្នកជំនាញ") ដើម្បីពិនិត្យវាយតម្លៃលើ នួន ជា និង ខៀវ សំផន ពីសម្បទារបស់ពួកគាត់ក្នុងការចូលរួមសវនាការ និងធ្វើរបាយការណ៍ពីលទ្ធផលនៃការពិនិត្យជូនអង្គជំនុំជម្រះសាលាដំបូង[8]។ ជាដំបូង អ្នកជំនាញម្នាក់ៗត្រូវធ្វើសម្បថដើម្បីជួយដល់អង្គជំនុំជម្រះសាលាដំបូងដោយភាពស្មោះត្រង់ ដោយសម្ងាត់ និងអស់ពីសមត្ថភាព[9]។ បន្ទាប់ពីពិនិត្យវាយតម្លៃលើជនជាប់ចោទរួចមក អ្នកជំនាញត្រូវរៀបចំរបាយការណ៍ជាលាយលក្ខណ៍អក្សររួមគ្នាមួយ ស្ដីពីសកម្មភាព លទ្ធផលនៃការពិនិត្យ និងសេចក្ដីសន្និដ្ឋានរបស់ខ្លួនចំពោះជនជាប់ចោទម្នាក់ៗ។ របាយការណ៍នីមួយៗត្រូវរួមបញ្ចូលនូវសេចក្ដីបញ្ជាក់របស់អ្នកជំនាញថា អ្នកជំនាញបានធ្វើការពិនិត្យ និងបានធ្វើរបាយការណ៍ដោយខ្លួនឯងផ្ទាល់។ អង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឱ្យអ្នកជំនាញធ្វើការទំនាក់ទំនងជាមួយនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន សម្រាប់គោលបំណងនេះ។

៦. របាយការណ៍របស់អ្នកជំនាញ ត្រូវរួមបញ្ចូលនូវព័ត៌មានដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានពិពណ៌នានៅក្នុងរឿងក្ដី Strugar[10] ដែលនឹងជួយដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការសម្រេច ថាតើជនជាប់-ចោទម្នាក់ៗមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការប្រកាសសាលក្រមដែរ ឬទេ។ ដើម្បីជួយដល់អង្គ-ជំនុំជម្រះសាលាដំបូងក្នុងការធានានូវការចូលរួមរបស់ នួន ជា និង ខៀវ សំផន ឱ្យមានប្រសិទ្ធភាពនៅក្នុងការជំនុំជម្រះលើពួកគេ អ្នកជំនាញក៏ត្រូវធ្វើការវាយតម្លៃ និងរាយការណ៍ផងដែរ ថាតើការរៀបចំជាក់លាក់

---

[8] អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានរកឃើញកាលពីលើកមុនថា ទាំងលោកវេជ្ជបណ្ឌិត CHAN Kin Ming និងវេជ្ជបណ្ឌិត ហួត លីណា គឺជាអ្នកជំនាញមានគុណវុឌ្ឍិ ហើយបានតែងតាំងពួកគេឱ្យធ្វើការវាយតម្លៃសម្បទារបស់ជនជាប់ចោទ។ សូមមើល ដីកាចាត់តាំងអ្នកជំនាញដើម្បីវាយតម្លៃលើសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ ឯកសារ E389 ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ ៥។

[9] វិធាន ៣១(២) នៃវិធានផ្ទៃក្នុង។

[10] រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Strugar អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY IT-01-42-T សេចក្ដីសម្រេចលើសំណើសុំរបស់មេធាវីការពារក្ដីសុំលុបចោលកិច្ចដំណើរការនីតិវិធី ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ២០០៤ កថាខណ្ឌ ៣៦ និងរឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Strugar អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY IT-01-42-A សាលដីកា ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០០៨ កថាខណ្ឌ ៥៥។

រួមទាំង ឧបករណ៍សោតទស្សន៍ ឆ្លើយតបបានគ្រប់គ្រាន់ទៅនឹងបញ្ហាសុខភាពរបស់ជនជាប់ចោទម្នាក់ៗដែរ ឬទេ។

៧. អនុលោមតាមភារកិច្ចនេះ អង្គជំនុំជម្រះសាលាដំបូង**បង្គាប់**ថា អ្នកជំនាញត្រូវ៖

ក. ពិនិត្យនូវរាល់របាយការណ៍ជំនាញ និងរបាយការណ៍វេជ្ជសាស្ត្រដែលពាក់ព័ន្ធទាំងអស់ និង សម្ភារៈនានាដែលមាននៅក្នុងសំណុំរឿងក្នុងពេលបច្ចុប្បន្ន និងសម្ភារៈនានាដែលត្រូវបានធ្វើឡើងដោយមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត អង្គភាពវេជ្ជសាស្ត្ររបស់ អ.វ.ត.ក. និងមន្ទីរពេទ្យផ្សេងទៀត។

ខ. ពិនិត្យជនជាប់ចោទម្នាក់ៗ ក្នុងគោលបំណងដើម្បីកំណត់នូវកម្រិតសុខភាពផ្លូវកាយ និងបញ្ហាស្មារតីរបស់គាត់ ក៏ដូចជាការវិនិច្ឆ័យទៅលើស្ថានភាពសុខភាព និងបញ្ហាស្មារតីរបស់ជនជាប់ចោទម្នាក់ៗ និងភាពល្អប្រសើរឡើង ឬ ភាពចុះដុនដាបនៃស្ថានភាពទាំងនេះ ចាប់តាំងពីមានការវាយតម្លៃផ្នែកវេជ្ជសាស្ត្រ និងបញ្ហាស្មារតីរបស់ជនជាប់ចោទ កាលពីពេលថ្មីៗកន្លងទៅនេះ។

គ. ធ្វើការពិគ្រោះយោបល់តាមការចាំបាច់ ជាមួយអ្នកជំនាញវេជ្ជសាស្ត្រ និងអ្នកជំនាញជំងឺផ្លូវចិត្តផ្សេងទៀត ដែលបានធ្វើរបាយការណ៍ជូនការិយាល័យសហចៅក្រមស៊ើបអង្កេតកាលពីលើកមុន អំពីស្ថានភាពរបស់ជនជាប់ចោទ ឬ ជាមួយវេជ្ជបណ្ឌិតដែលធ្លាប់បានព្យាបាលជំងឺរបស់ជនជាប់ចោទម្នាក់ៗ ឬ ពិនិត្យបញ្ហាផ្សេងទៀត ក្នុងអំឡុងពេលដែលពួកគាត់ស្ថិតនៅក្នុងមន្ទីរឃុំឃាំង អ.វ.ត.ក.។

ឃ. បង្ហាញនៅក្នុងរបាយការណ៍របស់ខ្លួនអំពីការវិនិច្ឆ័យណាមួយ និងការវិនិច្ឆ័យបន្ថែមទាំងអស់ដែលត្រូវបានបង្គាប់ដោយអ្នកជំនាញ ប៉ុន្តែត្រូវបានធ្វើឡើងដោយបុគ្គលផ្សេងទៀត រួមជាមួយនិងអត្តសញ្ញាណរបស់បុគ្គលទាំងនោះ។

ង. ជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង អំពីលទ្ធផលនៃការពិនិត្យផ្នែកវេជ្ជសាស្ត្រ និងការពិគ្រោះយោបល់ពាក់ព័ន្ធនឹងជនជាប់ចោទម្នាក់ៗ។

៨. អ្នកជំនាញត្រូវចាត់ទុកការងាររបស់ខ្លួនថាជាការសម្ងាត់ ដូចជា ការរក្សាការសម្ងាត់រវាងគ្រូពេទ្យ និងអ្នកជំងឺ ហើយមិនត្រូវលាតត្រដាងព័ត៌មានណាមួយ ស្តីពីលទ្ធផលនៃការពិនិត្យ សេចក្តីសន្និដ្ឋាន ឬ ការធ្វើរោគវិនិច្ឆ័យលើជនជាប់ចោទ ឬ របាយការណ៍លើបញ្ហានេះឡើយ លើកលែងតែការបង្ហាញជូនអង្គជំនុំជម្រះសាលាដំបូង ឬ ជូនអ្នកជំនាញដែលទទួលការបណ្តុះបណ្តាលផ្នែកវេជ្ជសាស្ត្រផ្សេងទៀត នៅក្នុងអំឡុងពេលធ្វើការពិគ្រោះយោបល់ទាំងឡាយ ដូចបានយោងនៅក្នុងកថាខណ្ឌ ៧(គ) ខាងលើ។ អ្នកជំនាញត្រូវមានអ្នកបកប្រែ

ភាសាដើម្បីជួយដល់ពួកគាត់ ព្រមទាំងជំនួយការជាជនជាតិខ្មែរ ដែលបានទទួលការបណ្តុះបណ្តាលផ្នែកវេជ្ជ-សាស្ត្រ ដែលមានកាតព្វកិច្ចគោរពនូវការសម្ងាត់នៃការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រ និងរបាយការណ៍។

៩. អ្នកជំនាញត្រូវប្រតិបត្តិតាមសេចក្តីបង្គាប់ទាំងនេះ ហើយក្រៅពីនេះ អ្នកជំនាញត្រូវបានចងភ្ជាប់កាតព្វកិច្ចដោយបទប្បញ្ញត្តិជាធរមានទាំងអស់នៃវិធាន ៣១ និងវិធាន ៣២ នៃវិធានផ្ទៃក្នុង។

១០. តាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញ និងផ្នែកគ្រប់គ្រងតុលាការ អង្គជំនុំជម្រះសាលាដំបូងនឹងផ្តល់ជូនអ្នកជំនាញនូវរាល់ឯកសារសម្ងាត់ទាំងអស់ពាក់ព័ន្ធផ្នែកវេជ្ជសាស្ត្រ ដែលមាននៅក្នុងសំណុំរឿងនាពេលបច្ចុប្បន្ន។ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ត្រូវសម្របសម្រួលឱ្យមានអ្នកបកប្រែភាសាដើម្បីជួយដល់អ្នកជំនាញនៅក្នុងអំឡុងពេលនៃការបំពេញភារកិច្ចរបស់ពួកគាត់។

១១. អ្នកបកប្រែភាសា បុគ្គលិកពេទ្យ និងអ្នកផ្សេងទៀតដែលជួយដល់អ្នកជំនាញ ឬ ជួយសម្រួលដល់ការពិនិត្យផ្នែកវេជ្ជសាស្ត្រលើជនជាប់ចោទ ត្រូវគោរព និងប្រតិបត្តិតាមដីកានេះ និងត្រូវរក្សាការសម្ងាត់លើការពិនិត្យផ្នែកវេជ្ជសាស្ត្រ លទ្ធផលនៃការពិនិត្យ និងរបាយការណ៍របស់អ្នកជំនាញ។

**យោងតាមសំអាងហេតុដូចបានលើកឡើងខាងលើ អង្គជំនុំជម្រះសាលាដំបូងសម្រេច៖**

**ចាត់តាំង** វេជ្ជបណ្ឌិត CHAN Kin Ming និងវេជ្ជបណ្ឌិត ហួត លីនណា ដើម្បីពិនិត្យ វាយតម្លៃជនជាប់ចោទ នួន ជា និង ខៀវ សំផន អនុលោមតាមដីកានេះ។

**ជូនដំណឹង** ដល់ភាគីថា ការពិនិត្យផ្នែកវេជ្ជសាស្ត្រលើជនជាប់ចោទ នឹងត្រូវធ្វើឡើងនៅថ្ងៃទី ២៩ និងថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៨ ហើយរបាយការណ៍ជាលាយលក្ខណ៍អក្សរសម្រាប់ជនជាប់ចោទម្នាក់ៗ នឹងធ្វើការពិនិត្យសម្រេចចុងក្រោយជាភាសាអង់គ្លេសដើម្បីដាក់ជូនអង្គជំនុំជម្រះសាលាដំបូងនៅត្រឹមថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៨ និងសំណៅនៃរបាយការណ៍ជាភាសាអង់គ្លេសនឹងបញ្ជូនទៅភាគីនៅត្រឹមថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៨ ហើយសំណៅនៃរបាយការណ៍ដែលបានបកប្រែរួចនឹងផ្តល់ជូនមេធាវីការពារក្តីជនជាប់ចោទនៅត្រឹមថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៨។

**កត់សម្គាល់ថា** ប្រសិនបើមានតម្រូវការពីអង្គជំនុំជម្រះនោះ អ្នកជំនាញនឹងត្រូវធ្វើការបង្ហាញលទ្ធផលនៃការពិនិត្យផ្នែកវេជ្ជសាស្ត្ររបស់ខ្លួន និងឆ្លើយតបទៅនឹងសំណួររបស់ភាគីនានា នៅក្នុងសវនាការដែលត្រូវធ្វើឡើងនៅថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០១៨។

សំណុំរឿង០០២/១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ

E460

**ស្នើសុំ** ការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក. និងមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ផ្តល់នូវជំនួយចាំបាច់ទាំងអស់ដល់អ្នកជំនាញសម្រាប់រយៈពេលនៃការបំពេញភារកិច្ចរបស់ពួកគាត់។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៧

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE DE PREMIÈRE INSTANCE

**និល ណុន**